# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## ដំណឹងជ្រើសរើសបេក្ខជនចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន សម្រាប់អ្នកសិក្សាភាសាជប៉ុន

លេខ: 24 PR-19/EoJ ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩

ស្ថានទូតជប៉ុនសូមជម្រាបជូនដល់អ្នកដែលបានជាប់តេស្តសមត្ថភាពភាសាជប៉ុន (JLPT) កម្រិត N4 នៃការប្រឡងក្នុងឆ្នាំ២០១៨ឲ្យបានជ្រាបថា ស្ថានទូតជប៉ុននឹងជ្រើសរើសបេក្ខជន១រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន។

បេក្ខជន១រូប នឹងត្រូវបានជ្រើសរើស ក្នុងចំណោមបេក្ខជនដែលដាក់ពាក្យ ដោយយោងទៅលើ លក្ខខណ្ឌជ្រើសរើស ព្រមទាំងលទ្ធផល នៃការប្រឡងតេស្តសមត្ថភាពភាសាជប៉ុនកម្រិត N4 និងការសម្ភាសន៍។

### លក្ខខណ្ឌជ្រើសរើស

១. សិស្សកំពុងសិក្សាភាសាជប៉ុន ឬ បានបញ្ចប់ការសិក្សាភាសាជប៉ុន នៅវិទ្យាស្ថានអប់រំភាសាជប៉ុនណាមួយនៅកម្ពុជា។

២. ជាប់តេស្តសមត្ថភាពភាសាជប៉ុនកម្រិត N4 នៅការប្រឡង JLPT នាឆ្នាំ២០១៨។

៣. អាចចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី៤ ដល់ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩។

៤. មិនមែនជាគ្រូភាសាជប៉ុននាពេលបច្ចុប្បន្ន។

៥. មិនមែនជាបេក្ខភាពដែលបានជ្រើសរើសជាគ្រូភាសាជប៉ុន។

៦. មិនមែនជាបុគ្គលិកស្ថានទូតជប៉ុន ឬ បុគ្គលិកមូលនិធិជប៉ុន។

៧. មានអាយុចាប់ពី១៨ឆ្នាំ ដល់ ៥៤ឆ្នាំ គិតត្រឹមថ្ងៃចាប់ផ្តើមវគ្គបណ្តុះបណ្តាល (អាយុកើតនៅចន្លោះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៦៥ រហូតដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០១) សម្រាប់បេក្ខជនដែលមានអាយុក្រោម២០ឆ្នាំ ត្រូវមានការអនុញ្ញាតពីអាណាព្យាបាល។

៨. មិនធ្លាប់ស្នាក់នៅប្រទេសជប៉ុនលើសពី៧ថ្ងៃ ក្នុងរយៈពេល៥ឆ្នាំ គិតត្រឹមថ្ងៃចាប់ផ្តើមវគ្គបណ្តុះបណ្តាល។

៩. មិនធ្លាប់សិក្សាកម្រិតបឋម ឬ មធ្យម នៅប្រទេសជប៉ុនរយៈពេលច្រើនជាង៣ឆ្នាំ។

១០. មិនមានគម្រោងទៅបន្តការសិក្សា ឬ ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងទៀត នៅប្រទេសជប៉ុន គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២០។

១១. មានសញ្ជាតិខ្មែរ និងមានទីលំនៅអចិន្ត្រៃយ៍នៅប្រទេសកម្ពុជា។

បេក្ខជនដែលបំពេញគ្រប់លក្ខខណ្ឌទាំងលើនេះ សូមដាក់ពាក្យមកកាន់ ស្ថានទូតជប៉ុន ឬតាមរយៈអ៊ីម៉េល ដោយភ្ជាប់មកជាមួយនូវ ពាក្យសុំ លិខិតបញ្ជាក់លទ្ធផលតេស្តN4 និងពិន្ទុតេស្ត N4។

<u>**កាលបរិច្ឆេទថ្ងៃផុតកំណត់ទទួលពាក្យសុំ ត្រឹមថ្ងៃសុក្រ ទី១៩ ខែមេសា ឆ្នាំ២០១៩**</u>

※ ឯកសារដែលដាក់ជូនស្ថានទូតមិនអាចដកវិញបានទេ។

## ព័ត៌មាននៃកម្មវិធីបណ្តុះបណ្តាល

**កាលបរិច្ឆេទ៖** ពីថ្ងៃពុធ ទី៤ ខែកញ្ញា ដល់ ថ្ងៃពុធ ទី១៨ ខែកញ្ញា ឆ្នាំ២០១៩ រយៈពេល១៥ថ្ងៃ

**ទីកន្លែងសិក្សា និងស្នាក់នៅ៖** ខេត្តអូសាកា (មជ្ឈមណ្ឌលអន្តរជាតិKansai នៃមូលនិធិជប៉ុន)

**ខ្លឹមសារនៃវគ្គបណ្តុះបណ្តាល៖**

១. ការបង្រៀនអំពីភាសាជប៉ុន និងប្រទេសជប៉ុន

២. ទទួលយកបទពិសោធន៍វប្បធម៌ជប៉ុនដោយផ្ទាល់

៣. ចុះកម្មសិក្សាតាមកន្លែងវប្បធម៌ និងប្រាសាទបុរាណនានា

៤. ទស្សនកិច្ចនៅផ្ទះប្រជាជនជប៉ុនដោយផ្ទាល់

**ទំនាក់ទំនងដាក់ពាក្យ និងសាកសួរព័ត៌មានបន្ថែម**

ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ៊ីម៉េល** info.jpn@pp.mofa.go.jp

**លេខទូរស័ព្ទ** ០២៣ ២១៨ ៨៧០ ភ្ជាប់បន្ត ១១២២

**ម៉ោងធ្វើការ** ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ 8:00-12:00, 13:30-17:15